# សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន
# រ៉ូប៊ើត ហ្សេលិក
# ប្រធានធនាគារពិភពលោក
# ក្លឹបសារព័ត៌មានជាតិ ទីក្រុងវ៉ាស៊ីនតោន
# ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៧

មកដល់ពេលនេះខ្ញុំបានបំរើតួនាទីជាប្រធានធនាគារពិភពលោកបាន ១០០ ថ្ងៃហើយ ហើយខ្ញុំសូមយកឱកាសនេះ ចែករំលែកចំណាប់អារម្មណ៍ និងគំនិតរបស់ខ្ញុំ ចំពោះទិសដៅជាយុទ្ធសាស្ត្រ ។

ខ្ញុំរីករាយចំពោះការលើកទឹកចិត្ត និងគាំទ្រ ដែលខ្ញុំបានទទួលពីផ្នែកជាច្រើន ។ ខ្ញុំយល់ឃើញថាប្រជាជននៅជុំវិញពិភពលោក ទាំងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍន៍ ទទួលស្គាល់ ទាំង តំរូវការ និងសក្តានុពលសំរាប់ការបង្កើតការទទួលស្គាល់តែមួយនេះ ។ ធនាគារពិភពលោក គឺជាស្ថាប័នពហុភាគីដ៏ធំបំផុតមួយដែលបានបង្កើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ។ ៦០ ឆ្នាំក្រោយមក ធនាគារពិភពលោក ត្រូវតែតំរូវទៅតាមកាលៈទេសៈដែលមានភាពខុសគ្នាធំធេងក្នុងសម័យថ្មីមួយនៃសកលភាវូបនីយកម្ម ។

បុគ្គលិករបស់ធនាគារពិភពលោក បានជួយខ្ញុំបានរៀនសូត្រ បង្ហាញខ្ញុំអំពីការងារដ៏មានសារៈសំខាន់របស់យើងនៅតាមប្រទេសនានា និង ផ្តល់ឱ្យខ្ញុំនូវគំនិតថ្មីៗ ដើម្បីរៀបចំការងារសំរាប់អនាគត ។ ក្រុមប្រឹក្សាភិបាល កំពុងតែផ្តល់នូវការណែនាំប្រកបដោយបទពិសោធន៍នៅពេលដែលយើងរៀបចំកែប្រែពីបំណងល្អៗ និង ការវិភាគនានាឱ្យទៅជាសកម្មភាពផលិតចេញជាសមិទ្ធិផល ។

## រូបភាពរបស់ធនាគារពិភពលោក

រូបភាពពិតៗរបស់ធនាគារពិភពលោក គឺមិនមែនអ្វីដែលយើងតែងតែឃើញនៅវ៉ាស៊ីនតោន ឬនៅក្នុងបន្ទប់របស់ម្ចាស់ទុនធំៗរបស់យើងនោះទេ ។

នៅពេលដែលខ្ញុំទៅដល់ខេត្ត យិន បៃ ដែលមានទីតាំងនៅតំបន់ភ្នំភាគខាងជើងប្រទេសវៀតណាម កាលពីខែ សីហា កន្លងទៅនេះ ខ្ញុំបានជួបស្ត្រីម្នាក់ ដែលពេលនេះគាត់មានភ្លើងអគ្គិសនីប្រើប្រាស់ដើម្បីជួយកិនស្រូវ បូមទឹក ប្រើកង្ហារ និងភ្លើងអគ្គិសនីបំភ្លឺបន្ទប់មួយដែលកូនរបស់គាត់អាចមើលមេរៀនបាននៅពេលយប់

នេះដោយសារតែធនាគារពិភពលោក បានគាំទ្រហិរញ្ញវត្ថុដល់គំរោងអគ្គិសនីប្រទេសវៀតណាម ។ ប្រជាជនវៀតណាម ពេលនេះមានជាង ៩0 ភាគរយ មានភ្លើងអគ្គិសនីប្រើប្រាស់ ។ ដូចគ្នានឹងសង្គមផ្សេងៗទៀតដែរ អគ្គិសនីជនបទជួយផ្តល់ឱកាសដល់ស្ត្រីដែលពួកគាត់ជាកំលាំងដ៏សំខាន់នៅក្នុងការងារស្រែចំការប្រចាំថ្ងៃ ។

នៅប្រទេសហង់ដួរ៉ាស ធនាគារពិភពលោកកំពុងតែជួយសង្គ្រោះឧទ្យានជាតិ Pico Bonito តាមរយៈ មូលនិធិកាបូនជីវៈ គាំទ្រកសិករ ដែលផ្លាស់ប្តូរពីការកាត់ដើម Redondo ដើម្បីលក់គ្រាប់ជំនួសដោយការ ដាំឡើងវិញនូវកូនឈើតូចៗ ។ កសិករម្នាក់មានប្រសាសន៍ថា "យើងនៅតែមានដើមឈើរបស់យើង ។ ខ្ញុំ អាចរកលុយបាន ហើយបានច្រើនជាងមុនទៅទៀត ។ លើសពីនេះយើងបានថែរក្សាកូនឈើព្រៃធម្មជាតិទាំង នោះទៀតផង" ។

នៅប្រទេសនីសេរីយ៉ា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ជាផ្នែកមួយខាងវិស័យឯកជនរបស់យើង ជួយស្ត្រីជាម្តាយម្នាក់នៅភូមិ Ovoko ឱ្យទទួលបានកម្ចីមីក្រូឥណទានមួយ ហើយបានក្លាយទៅជាការិនីទូរស័ព្ទនៅក្នុងភូមិនោះ ។ អ្នកភូមិនៅទីនោះធ្លាប់បានចំណាយពេលធ្វើដំណើរពេញមួយថ្ងៃដើម្បីទៅទូរស័ព្ទម្តងៗ ។ ពេលនេះ កន្លែងទូរស័ព្ទនេះជួយអ្នកភូមិ អាចទាក់ទងបានទូលំទូលាយជាមួយពិភពខាងក្រៅ កំរៃពីរបរនេះនាងអាចបង់ថ្លៃឱ្យកូនៗរៀន ហើយទិញថ្នាំសង្កូវមកព្យាបាលជំងឺ HIV/AIDs ដែលនាងផ្ទុក ។

ការផ្តល់ឱកាសនេះ ប្រជាជននៅគ្រប់ទីកន្លែងចង់កសាងជីវិតឱ្យប្រសើរសំរាប់ខ្លួនគេ និងសំរាប់កូនៗរបស់ពួកគេ ។ ដូច្នេះ នេះជាការជំរុញមួយ ប្រសិនបើពួកគាត់ត្រូវបានគេផ្តល់ឱកាសឱ្យ នោះអាចរួមចំណែកយ៉ាងច្រើនដល់សុខមាលភាព និងភាពរីកចំរើននៅក្នុងសង្គមពិភពលោកទាំងមូល ។

## សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន : គំរូចការ

យើងរស់នៅក្នុងសម័យនៃសកលភាវូបនីយកម្ម ។ ប៉ុន្តែរាងរៅរបស់វាមិនទាន់មានភាពនឹងន់នៅឡើយ ។ ចាប់តាំងពីការបញ្ចប់សង្គ្រាមត្រជាក់ ប្រជាជនរស់នៅក្នុងសេដ្ឋកិច្ចទីផ្សារពិភពលោកបានកើនឡើងពី ១ ពាន់លាននាក់ ទៅ ៤ ឬ ៥ ពាន់លាននាក់ បង្កើនកំលាំងពលកម្មយ៉ាងច្រើន ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងមណ្ឌលសេវាកម្មនានានៅតាមប្រទេសកំពុងអភិវឌ្ឍ ជំរុញឱ្យមានការទាមទារថាមពល និងរបស់របរប្រើប្រាស់ និងបង្កើតឱ្យមានកំណើនខាងតំរូវការ ។ ការដាក់ហ៊ុនថ្មីនៃការសន្សំកំពុងតែបំពេញបន្ថែមដល់លំហូរទុនសកលដែលទាក់ទាញឱ្យមានឱកាសសំរាប់វិនិយោគ ផ្តល់ឱ្យទាំងប្រទេសដែលទីផ្សារទើបតែ

ងើបឡើង និងប្រទេសដែលផ្លាស់ប្តូរទៅជាប្រទេសអភិវឌ្ឍន៍ ។ ការផ្ទេរជំនាញ បច្ចេកវិទ្យា ព័ត៌មាន និងការប្រែក្លាយចំណេះដឹងទាំងនោះទៅជាការអនុវត្ត កំពុងតែមានល្បឿនទៅមុខ ។

លំហូសកលនៃពាណិជ្ជកម្មបានកើនឡើងច្រើនទ្វេដងចាប់តាំងពីឆ្នាំ ១៩៩០ ។ ការបើកចំហរសេដ្ឋកិច្ចច្រើនធ្វើឱ្យតំលៃទំនិញ និងសេវាកម្មថយចុះ ។ ប្រទេសកាន់តែច្រើនថែមទៀតកំពុងអាស្រ័យលើការនាំចេញសំរាប់នាំមុខកំណើន ។ ខណៈពេលដែលការទិញពីប្រទេសអភិវឌ្ឍន៍នៅតែដើរតួនាទីសំខាន់ ទំរង់ពាណិជ្ជកម្មថ្មីឆ្លុះបញ្ចាំងខ្សែចង្វាក់ផ្គត់ផ្គង់នៅក្នុងតំបន់ និងពិភពលោក និងបង្កើនពាណិជ្ជកម្មរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍គ្នាឯង ។ មានប្រជាជនជាង ៣០០ លាននាក់ បានចាកចេញផុតពី ភាពក្រីក្រតោកយ៉ាកខ្លាំង ។

ប៉ុន្តែនៅមានរឿងច្រើនទៀតនៅមិនទាន់ចូលរួមក្នុងសកម្មភាពទាំងនេះ និងខ្លះស្ថិតនៅក្រោយគេឆ្ងាយ ។ រឿងទាំងនោះអាចរាប់បានថា ជាប្រទេស តំបន់ និងក្រុមនៅក្នុងប្រទេសទាំងនោះ ឬអាចជាបុគ្គលមួយរូប១ ។ ការមិនចូលរួមរបស់ពួកគេបង្កបញ្ហាជាច្រើន ដូចជា ជំលោះ អភិបាលកិច្ចខ្សោយ និងអំពើពុករលួយ ការរើសអើង ខ្វះខាតតំរូវការមូលដ្ឋានរបស់មនុស្ស ខ្វះសិទ្ធិលើកម្មសិទ្ធិ និងនីតិរដ្ឋ ហើយបង្កបញ្ហាដល់ភូមិសាស្ត្រ និងអាកាសធាតុ ។

យើងក៏ឃើញបញ្ហាប្រឈមខាងបរិស្ថាននៃការកើនឡើងកំណើននេះដែរ ដូចជាទន្លេហូជាមួយទឹកខ្មៅក្រខ្វក់ ផ្ទៃមេឃបាំងបិទពន្លឺព្រះអាទិត្យ និងការកំរាមកំហែងដល់សុខភាព និងបរិស្ថាន ។

សកលភាវូបនីយកម្ម ផ្តល់ឱកាសហួសពីការជឿបាន ។ ប៉ុន្តែការមិនដាក់បញ្ចូលការលុបបំបាត់ភាពក្រីក្រ និង លុបបំបាត់ការបំផ្លាញបរិស្ថាន បង្កើតជាគ្រោះថ្នាក់ ។ អ្នកដែលទទួលរងគ្រោះថ្នាក់នេះច្រើនជាងគេ គឺអ្នកដែលមានឱកាសតិចតួចសំរាប់ចាប់ផ្តើម ដូចជា ជនជាតិដើមភាគតិច ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ប្រជាជនក្រីក្រនៅតាមជនបទ ប្រជាជនអាហ្វ្រិក និងនៅកូនចៅរបស់ពួកគេ ។

វាគឺជាទស្សនៈរបស់ធនាគារពិភពលោក ដើម្បីរួមចំណែកក្នុងសកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និង ប្រកបដោយនិរន្តរភាពបរិស្ថាន ដោយព្យាយាមដោះស្រាយភាពក្រីក្រ លើកកំពស់កំណើនជាមួយនឹងការថែរក្សាបរិស្ថាន និង ការបង្កើតឱកាស និងមានសង្ឃឹម ដល់បុគ្គលម្នាក់១ ។

នៅឆ្នាំ ២០០០ ប្រទេសដែលជាសមាជិករបស់អង្គការសហប្រជាជាតិបានបង្កើតគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ចំនួន ៨ ដែលមានមហិច្ឆតាកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាល ប្រយុទ្ធនឹងភាពអត់ឃ្លាន និង ជំងឺ និងការផ្តល់សេវាមូលដ្ឋានដល់ប្រជាជនក្រីក្រ រហូតដល់ឆ្នាំ ២០១៥ ។ គោលដៅទាំងនេះ រួមទាំងគោលដៅរបស់យើងបានដាក់តាំងនៅខ្លោងទ្វារធំរបស់យើងនៅការិយាល័យកណ្តាល ដើម្បីរំឭកយើងជាប្រចាំនូវអ្វីដែលយើងត្រូវធ្វើឱ្យបានសំរេច ។

គោលបំណងនៃការអភិវឌ្ឍសង្គមនេះ ត្រូវតែភ្ជាប់គ្នាជាមួយនឹងសេចក្តីត្រូវការសំរាប់កំណើនប្រកបដោយនិរន្តរភាព ដែលនាំមុខដោយវិស័យឯកជន និងមានការគាំទ្រជាក្របខ័ណ្ឌនៃគោលនយោបាយសាធារណៈ ។

## ចាប់អារម្មណ៍ទៅលើតំរូវការមូលដ្ឋានខ្លះៗ

ជារៀងរាល់ឆ្នាំ ជំងឺគ្រុនចាញ់ វាតត្បាតដល់មនុស្សជាង ៥០០ លាននាក់នៅលើពិភពលោក ។ ប៉ុន្តែយើងអាចជំនះដោះស្រាយមេរោគដែលជាឃាតករនាំមុខគេដែលសំលាប់ក្មេងៗនៅអាហ្វ្រិកនេះបាន ។ វាត្រូវការវិនិយោគមួយដែលមានទឹកប្រាក់ប្រមាណ ៣ ពាន់លានដុល្លារ ក្នុងមួយឆ្នាំៗ ក្នុងអំឡុងពេល ២ ឬ ៣ ឆ្នាំខាងមុខ ដើម្បីផ្តល់ឱ្យគ្រួសារដែលងាយរងគ្រោះនឹងជំងឺគ្រុនចាញ់នេះ ដូចជាមុងការពារមូស ថ្នាំព្យាបាល និងបរិមាណដ៏សមហេតុផលនៃថ្នាំសំលាប់សត្វល្អិតផ្ទែកខាងក្នុងផ្ទះសំបែង ។

ភ្នាក់ងារថាមពលអន្តរជាតិ ប៉ាន់ប្រមាណថា ប្រទេសកំពុងអភិវឌ្ឍ នឹងត្រូវការទឹកប្រាក់វិនិយោគប្រមាណ ១៧០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំៗ ចំពោះវិស័យថាមពល ក្នុងអំឡុងពេលមួយទសវត្សរ៍ខាងមុខ ហើយជាមួយនឹងការរក្សានូវតំរូវការថាមពលនេះឱ្យបន្តបាន ត្រូវមាន ៣០ ពាន់លានដុល្លារបន្ថែមទៀតក្នុងមួយឆ្នាំៗ សំរាប់ធ្វើឱ្យប្រភពថាមពលដែលបំភាយឧស្ម័នកាបូនិចទាបដំណើរការបាន ។

ប្រាក់បន្ថែម ៣០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំៗ គឺត្រូវការដើម្បីទទួលបានជោគជ័យចំពោះគោលដៅសហសវត្សរ៍នៃការផ្គត់ផ្គង់ទឹកប្រកបដោយសុវត្ថិភាពដល់មនុស្ស ១,៥ ពាន់លាននាក់ និងផ្តល់អនាម័យដល់មនុស្ស ២ ពាន់លាននាក់ ដែលពួកគេខ្វះខាតតំរូវការមូលដ្ឋាននេះ ហើយក៏កែលំអសមភាពយេនឌ័រនៅប្រទេសក្រីក្រផងដែរ ។

មានតំរូវការប្រមាណជា ១៣០ ពាន់លានដុល្លារទៀតក្នុងមួយឆ្នាំៗ ដើម្បីបំពេញនូវតំរូវការហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលចេះតែកើតមានឡើងនៅប្រទេសកំពុងអភិវឌ្ឍ ហើយក៏រួមនឹងទឹកប្រាក់ប្រមាណ ១០ ពាន់លានដុល្លារទៀតក្នុងមួយឆ្នាំៗ សំរាប់សំណង់ស្ថានីយលើកដាក់កុងទីន័រនៅតាមសមុទ្រដែលផ្តល់ឱកាសដល់ការធ្វើពាណិជ្ជកម្ម ។

ដើម្បីផ្តល់ការអប់រំបឋមដល់ក្មេងប្រមាណ ៨០ លាននាក់ដែលមិនបានរៀនសូត្រ ហើយវាជាគោលដៅសហសវត្សរ៍មួយដែរនោះ ប្រទេសដែលទទួលបានប្រាក់ចំណូលតិច នឹងត្រូវការប្រមាណ ៧ ពាន់លានដុល្លារ ក្នុងមួយឆ្នាំៗ ។

## តើធនាគារពិភពលោកអាចជួយតាមរបៀបណា

ដើម្បីសំរេចបានការងារនេះមិនមែនគ្រាន់តែជារឿងលុយនោះទេ ។ ហើយក៏មិនមែនតួនាទីរបស់ធនាគារផ្តល់ហិរញ្ញវត្ថុវិនិយោគដោយខ្លួនឯងនោះដែរ ។

នេះគឺជាគោលបំណងរបស់ធនាគារពិភពលោក ជួយប្រទេសនោះ ឱ្យជួយខ្លួនឯងដោយបង្កើតជាកត្តាលីករមូលធន និង គោលនយោបាយតាមរយៈការរួមបញ្ចូលគំនិត និងបទពិសោធន៍ចូលគ្នាតែមួយ ការអភិវឌ្ឍឱកាសទីផ្សារឯកជន និងការគាំទ្រអភិបាលកិច្ចល្អ និងប្រឆាំងអំពើពុករលួយ ដែលផ្តល់ឱ្យដោយធនធានហិរញ្ញវត្ថុរបស់យើង ។

វាជាគោលបំណងរបស់ធនាគារពិភពលោក ក្នុងការអភិវឌ្ឍគំនិតស្តីអំពីគំរោងអន្តរជាតិ និង កិច្ចព្រមព្រៀងនានាស្តីអំពីពាណិជ្ជកម្ម ហិរញ្ញវត្ថុ សុខភាព ភាពក្រីក្រ ការអប់រំ និងការប្រែប្រួលអាកាសធាតុ ដូចនេះពួកគេអាចទទួលបានផលប្រយោជន៍ទាំងអស់នេះ ជាពិសេសប្រទេសក្រីក្រដែលកំពុងស្វែងរកឱកាសថ្មី ។

យើងគួតែពង្រីកនូវដែនកំណត់នៃការគិតគូអំពីគោលនយោបាយ និងទីផ្សារ និងលទ្ធភាពនៃការចាប់ផ្តើមថ្មី ឱ្យលើសពីអ្វីដែលយើងបានធ្វើដដែល ជាមួយនឹងការផ្តល់ឱកាសហិរញ្ញវត្ថុដ៏សមហេតុសមផលមួយ ។

ខ្ញុំសូមលើកយកគោលគំនិតរបស់ក្រុមធនាគារពិភពលោកមកបង្ហាញ ។ ពិតមែនតែជាក្រុម តែយើងជាស្ថាប័នតែមួយដែលប្រតិបត្តិការតាមរយៈបុគ្គលិកប្រកបដោយឯកទេស ដូចស្ថាប័នហិរញ្ញវត្ថុធំៗជាច្រើន។ យើងត្រូវតែពង្រឹងអន្តរកម្ម និងប្រសិទ្ធិភាពរបស់យើងដែលជាក្រុមតែមួយ ។

ក្រុមរបស់យើងជាគោលការណ៍មានចំនួន ៤ ផ្នែក ។ ធនាគារអន្តរជាតិសំរាប់ការស្តារឡើងវិញ និង អភិវឌ្ឍន៍ (IBRD) គឺជាផ្នែកហិរញ្ញវត្ថុសាធារណៈរបស់យើង ដោយផ្តល់ប្រាក់កម្ចីផ្អែកទៅលើតំលៃទីផ្សារ ការគ្រប់គ្រងហានិភ័យ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត ដោយភ្ជាប់ទៅជាមួយនូវបទពិសោធន៍នៃការអភិវឌ្ឍ ពេញលេញ ។ សមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) គឺជាភ្នាក់ងារផ្តល់ជំនួយដែលផ្តល់កម្ចីដែលគ្មានការប្រាក់ និង ជំនួយឥតសំណងទៅដល់ប្រទេសក្រីក្របំផុត ៨១ ប្រទេសនៅលើពិភពលោក ក៏ដូចជាការជួយសង្គ្រោះ បំណុលដ៏ធំសំបើមផងដែរ ។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) គឺជាផ្នែកវិស័យឯកជនរបស់យើង ដោយ ផ្តល់ការវិនិយោគភាគហ៊ុន កម្ចី និងធានារ៉ាបរង និងផ្តល់សេវាប្រឹក្សាដល់ប្រទេសកំពុងអភិវឌ្ឍ ។ មួយទៀត គឺភ្នាក់ងារធានារ៉ាបរងការវិនិយោគពហុភាគី (MIGA) ដោយផ្តល់ជាការធានាចំពោះហានិភ័យ ខាងនយោបាយ ។ មធ្យោបាយប្រតិបត្តិការរួមគ្នារបស់យើងធ្វើឱ្យធនាគារពិភពលោកទាំងមូលមាន ដំណើរការទៅយ៉ាងប្រសើរ ជាជាងការរីកចំរើនតែមួយផ្នែកៗរបស់ខ្លួន ។

គ្រប់ផ្នែកទាំងអស់បានចែករំលែកជំនាញ មេរៀន និងបទពិសោធន៍ សំរាប់គ្របដណ្តប់លើការងារ អភិវឌ្ឍន៍ប្រកបដោយវិន័យច្បាស់លាស់ ។ ការផ្តល់ ការពង្រីក និងការសាកល្បងចំណេះដឹងនេះ (ទាំងពីរ ទាំងជាមួយហិរញ្ញវត្ថុ ឬ ដោយឡែក) គឺជាផ្នែកដ៏សំខាន់បំផុតនៃការងាររបស់យើង ។

## ជំហានដំបូង

រយៈពេលជាងពីរខែកន្លងទៅនេះ ដោយធ្វើការយ៉ាងជិតស្និតជាមួយក្រុមប្រឹក្សារបស់យើង គណៈ គ្រប់គ្រងរបស់ធនាគារពិភពលោក បានចាប់ផ្តើមអនុវត្តសកម្មភាពឈានឆ្ពោះទៅមុខ ។ ដើម្បីអនុវត្តការងារ នេះ យើងក៏ពង្រឹងកំលាំងអនុភាពក្នុងចំណោមអង្គភាពរបស់យើងទាំងអស់ ។

ឆ្នាំនេះ យើងកំពុងតែបំពេញបន្ថែមលើមូលនិធិសំរាប់ IDA ដែលជាផ្នែកដែលផ្តល់មធ្យោបាយខាង ហិរញ្ញវត្ថុសំរាប់ប្រទេសក្រីក្របំផុត ហើយជាពិសេសនៅប្រទេសអាហ្វ្រិក ។ ពេលនេះគឺជាការបំពេញបន្ថែម លើកទី ១៥ ឬ IDA-១៥ ដែលមូលនិធិបំពេញបន្ថែមនេះសំរាប់ប្រើប្រាស់រយៈពេលបីឆ្នាំទៅមុខ ។

យើងបានពិភាក្សាជាមួយប្រទេសដែលជាម្ចាស់ជំនួយជាង ៤0 ហើយក៏បានពិភាក្សាជាមួយប្រទេស ដែលជាអ្នកខ្ចី ឬអ្នកទទួលផងដែរ ថាតើយើងត្រូវកំណត់អាទិភាព ពង្រឹងគោលនយោបាយ និងការកែលំអ ប្រសិទ្ធិភាពរបស់យើងនៅក្នុងប្រទេសដែលគាំទ្រដោយ IDA បែបណា ។ សទ្ធាទានរបស់ម្ចាស់ជំនួយ គឺជា

គ្រឹះសំរាប់ការទទួលបានជោគជ័យនៃជំនួយបំពេញបន្ថែមនេះ ហើយយើងទទួលបានការលើកទឹកចិត្តដោយការគាំទ្រពីពួកគាត់សំរាប់លទ្ធផលដែលយើងចង់បាន ។

ខ្ញុំចង់ឱ្យម្ចាស់ជំនួយទាំងអស់ដឹង (ក្នុងន័យពិតត្រង់) ថា ធនាគារពិភពលោកនឹង "ផ្តល់លុយជាមួយនឹងប្រតិបត្តិការជាក់ស្តែង – put its money where its mouth is " នៅពេលចំពេលវេលាដែលត្រូវ គាំទ្រ IDA ។

ដូច្នេះ ខ្ញុំមានកិត្តិយសណាស់សូមប្រកាសថា ក្រុមប្រឹក្សារបស់យើង បានយល់ព្រមថាធនាគារពិភពលោក គួនាំផ្លូវដើម្បីស្វែងរកការបរិចាកជាធនធានផ្ទាល់ខ្លួនចំនួន ៣,៥ ពាន់លានដុល្លារ ដល់ IDA -15 ។ ទឹកប្រាក់នេះ ច្រើនជាងទ្វេរដង ដែលយើងបានសន្យាផ្តល់ឱ្យសំរាប់ IDA 14 កាលពីឆ្នាំ ២០០៥ ដែលមានទឹកប្រាក់តែ ១,៥ ពាន់លានដុល្លារ ។ ជាមួយនឹងកាសន្យាដ៏រឹងមាំនេះ យើងនឹងសុំឱ្យប្រទេសម្ចាស់ជំនួយជួយបង្កើនការសន្យារបស់គេដើម្បីជួយប្រទេសក្រីក្របំផុត ជាពិសេស ប្រទេសនៅអាហ្វ្រិក និង ប្រទេសនៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីខាងកើត ។ ប្រទេសនៅតំបន់អាហ្វ្រិកខាងត្បូង បានរៀបចំស្តង់ដារល្អរួចរាល់ហើយ ដោយសន្យាផ្តល់ ៣០ ភាគរយ ពីមូលនិធិ IDA របស់ខ្លួន ។ ឥឡូវនេះយើងត្រូវការប្រទេសដែលជាសមាជិក G-8 និង ប្រទេសអភិវឌ្ឍន៍ផ្សេងៗទៀត សូមឆ្លើយតបទៅនឹងចំនួនជាលេខទៅតាមអ្វីដែលខ្លួនបានប្រកាសនៅឯសន្និបាត ។

ពិតណាស់ ការចូលរួមចំណែកពី IDA របស់យើង គឺអាស្រ័យទៅនឹងចំណូលប្រចាំឆ្នាំ ពី IBRD និង IFC ដែលក្រុមប្រឹក្សារបស់ផ្នែកទាំងពីរនេះចូលរួមចំណែកជារាល់ឆ្នាំ ហើយយើងសង្ឃឹមថា គោលដៅដែលយើងពង្រីកដ៏ធំនេះ នឹងអាចទៅរួច ។ យើងសុំឱ្យអ្នកផ្សេងៗទៀតពង្រីកគោលដៅនេះដែរ ។

ទី២ យើងបានប្តេជ្ញាចំពោះយុទ្ធសាស្ត្រកំណើនដ៏រឹងមាំមួយសំរាប់ IFC ។ IFC គឺទទួលបានមូលធនដ៏ប្រសើរ ហើយកំពុងតែគាំទ្រការវិនិយោគវិស័យឯកជនរបស់ខ្លួននៅក្នុងប្រទេសដែលគាំទ្រដោយ IDA ប្រទេសដែលមានចំណូលទាប និងមធ្យម ហើយក៏គាំទ្រដល់តំរូវការតាមតំបន់ និងវិស័យនានា នៅក្នុងប្រទេសដែលមានចំណូលមធ្យមផងដែរ ។

ទី ៣ យើងនឹងពង្រឹងសហប្រតិបត្តិការរវាង IDA និង IFC ដើម្បីជំរុញវិស័យឯកជននៅក្នុងប្រទេសទាំងនោះ ។ ឆ្នាំកន្លងទៅ ៣៧ ភាគរយនៃការវិនិយោគរបស់ IFC គឺធ្វើឡើងនៅក្នុងប្រទេសដែលទទួលបាន

ការគាំទ្រដោយ IDA ហើយយើងនឹងបង្កើនតួរលេខនេះតទៅទៀត ។ IFC ក៏បានផ្សព្វផ្សាយមូលនិធិហេដ្ឋារចនាសម្ព័ន្ធ និងសមភាពមីក្រូ សំរាប់ប្រទេសដែលទទួលបានការគាំទ្រពី IDA ។ លើសពីនេះទៅទៀត IDA និង IFC អាចសហការគ្នាវិនិយោគដើម្បីគាំទ្រភាពជាដៃគូរវាងវិស័យសាធារណៈ និង ឯកជន នៅក្នុងគំរោងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស នៅក្នុងវិស័យថាមពល ការដឹកជញ្ជូន ទឹក កសិកម្ម និងវិស័យមីក្រូហិរញ្ញវត្ថុ ។ គំរោងទាំងនេះ អាចគាំទ្រសមាហរណកម្មនៃទីផ្សារក្នុងតំបន់ ជាពិសេសវាមានសារៈសំខាន់ណាស់ សំរាប់រដ្ឋដែលតូច និងដែលជុំជិតទៅដោយដី (គ្មានសមុទ្រ) នៅទ្វីបអាហ្វ្រិក ។

ទី ៤ ទោះបីជា IBRD មានទុនប្រសើរក៏ដោយ អាជីវកម្មកម្ចីរបស់យើងកំពុងតែមានការថយចុះ ។ ពេលនេះ ប្រមាណ ៧០ ភាគរយ នៃប្រជាជនក្រីក្រនៅប្រទេសឥណ្ឌា ចិន និងប្រទេសដែលមានចំណូលមធ្យម គឺ គាំទ្រដោយ IBRD ។ ប្រទេសទាំងនេះ នៅតែសុំឱ្យយើងនៅបន្តដដែលចំពោះការស្វែងរកវិធីសាស្ត្រប្រសើរនានាដើម្បីបំពេញតំរូវការដែលគេចង់បាន ។ ដូចនេះ ការងាររបស់ IBRD គួរតែកើនឡើងមិនមែនកិច្ចសន្យាកម្ចីទេ ។ ពិតណាស់ ដូចអ្វីដែលខ្ញុំនឹងពិភាក្សា សេវារបស់យើងសំរាប់ប្រទេសដែលមានចំណូលមធ្យម ត្រូវតែបន្តពង្រីកថែមទៀតលើសពីការឱ្យខ្ចីរបស់យើង ។ ប៉ុន្តែតំលៃចំណាយរបស់យើងច្រើននេះបានឆ្លុះបញ្ចាំងឱ្យមានការកែតំរូវកាលពីឆ្នាំ ១៩៩៨ ហើយពេលនោះធ្វើឱ្យអតិថិជនរបស់យើងមានការយល់ច្រឡំ ។ កម្ចី IBRD ជាមួយនឹងការកំណត់ និងជំនាញគោលនយោបាយនាំមុខគេ នៅតែមានតំលៃដដែល ។ សេវាចំរុះនៃការផ្តល់កម្ចី និងចំណេះដឹងរបស់យើង គឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីជួយប្រទេសក្នុងការអភិវឌ្ឍសង្គម និងការពង្រីកថាមពល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងបរិបទមួយដោយគិតគូអំពីផលប៉ះពាល់ដល់បរិស្ថាន ។

ដូច្នេះហើយ ដើម្បីបំពេញឱ្យបាននូវតំរូវការនៃការងើបឡើងចំពោះទីផ្សាររបស់ប្រទេសទាំងនោះ ខ្ញុំបានស្នើរសុំក្រុមប្រឹក្សារបស់យើងធ្វើឱ្យមានលក្ខណៈងាយស្រួល និងកាត់តំលៃរបស់យើង ដូចនេះហើយអាចពង្រីកការផ្តល់ប្រាក់កម្ចីរបស់យើង ដើម្បីគាំទ្រការអភិវឌ្ឍ និងកំណើន ។ ខ្ញុំមានការរីករាយណាស់ដែលក្រុមប្រឹក្សារបស់យើងយល់ស្រប ហើយបញ្ជាក់អំពីតំលៃបង់របស់យើង និង កាត់បន្ថយអត្រាការប្រាក់ស្មើរក៏រិតមួយមុនពេលមានវិបត្តិសេដ្ឋកិច្ចនៅអាស៊ី ។ ជំហាននេះ អាចជួយឱ្យយើងមានឱកាសសំរាប់ពង្រីកសេវារបស់យើង ។ ប៉ុន្តែយើងនៅមានការងារច្រើនថែមទៀតដែលត្រូវធ្វើ ។ យើងត្រូវតែដោះស្រាយតំលៃមិនមែនហិរញ្ញវត្ថុនៃការធ្វើធុរកិច្ច (អាជីវកម្ម) ។ យើងមានគោលបំណង ឱ្យការងារនេះដើរទៅមុខលឿន ប្រសើរហើយមានតំលៃថោក ។

ជំហានទាំងនេះទើបតែចាប់ផ្តើម ។ វាបានបង្ហាញផ្លូវឆ្ពោះទៅរកការពង្រីកដ៏ធំធេងមួយទៅអនាគត តាមរយៈការដៅចំណុចគោលយ៉ាងរឹងមាំ ។

## សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន : វិធីសាស្ត្រពហុភាគីមួយ

សកលភាវូបនីយកម្ម មិនត្រូវទុកឱ្យ "ប្រជាជនក្រីក្ររាប់ពាន់លាននាក់" នៅពីក្រោយនោះទេ ។ ការពោលអះអាងនេះ អាស្រ័យទៅលើអ្វីដែលលើសពីការគោរពនូវតំលៃរបស់ប្រជាជនប្រុសស្រីរបស់យើង ហើយលើសពីនោះទៅទៀត យើងម្នាក់ៗប្រហែលជាកើតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា។ សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ ក៏ជាបញ្ហាមួយនៃការគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ។ ភាពក្រីក្របង្ករអស្ថេរភាព ជំងឺ និងការវិនាសហិនហោចចំពោះធនធានធម្មជាតិ និង បរិស្ថាន ។ ភាពក្រីក្រ អាចនាំទៅរកការបាក់បែកសង្គម ដែលអាចក្លាយទៅជាកន្លែងនៃវិនាសកម្ម និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានជីវិត ។

សកលភាវូបនីយកម្ម ក៏នាំមកនូវអត្ថប្រយោជន៍មិនស្មើគ្នាចំពោះប្រជាជនរាប់ពាន់លាននាក់នៅក្នុងប្រទេសដែលមានចំណូលមធ្យម ដែលពួកគេចាប់ផ្តើមឡើងកាំជណ្តើរនៃការអភិវឌ្ឍ ចាប់តាំងពីការបញ្ចប់សង្គ្រាមត្រជាក់មក ។ ប្រទេសជាច្រើន ភាពតានតឹងផ្នែកសង្គម កំពុងតែធ្វើឱ្យទន់ខ្សោយភាពស្រុះស្រួលគ្នាខាងនយោបាយ ។ ប្រទេសដែលមានចំណូលមធ្យម គឺជាទីកន្លែងដែលមានព្រៃឈើប្រមាណ ៦០ ភាគរយនៃព្រៃឈើពិភពលោក ហើយ ៤០ ភាគរយ នៃការសាយភាពឧស្ម័នកាបូនិចនៅលើពិភពលោក កើនចេញពីចំហេះហ្វូសីល ។ ដោយរួមគ្នាជាមួយប្រទេសអភិវឌ្ឍន៍ ដែលផលិតនូវផលិតផលដែលមានការសាយភាពឧស្ម័នច្រើនជាងគេបំផុត ដូចនេះ ប្រទេសទាំងអស់នេះ នឹងជាគន្លឹះដើម្បីរុករកវិធីសាស្ត្រសកលដ៏ប្រសើរក្នុងការដោះស្រាយបំរែបំរួលអាកាសធាតុ ។ ប្រទេសដែលមានចំណូលមធ្យមទាំងនេះ ត្រូវការបន្តកំណើន និងត្រូវការបញ្ចូលក្នុងការអភិវឌ្ឍ និងការទទួលយកនូវគោលនយោបាយដែលគិតគូរដល់បរិស្ថានសំរាប់វិបុលភាពប្រកបដោយនិរន្តរភាព ។

ឥទ្ធិពលដ៏ខ្លាំងក្លានៃប្រទេសកំពុងអភិវឌ្ឍ បង្ហាញជាសំណួរមួយទៀត : តើអ្វីជាការចូលរួមរបស់ពួកគេនៅក្នុងការអភិវឌ្ឍប្រព័ន្ធសកលនេះ? នេះមិនមែនជាសំណួរតែមួយ ដែលថាតើប្រទេសកំពុងអភិវឌ្ឍធំៗ នឹងធ្វើអន្តរកម្មជាមួយប្រទេសអភិវឌ្ឍន៍យ៉ាងណា ហើយក៏ដូចជាការធ្វើអន្តរកម្មជាមួយប្រទេសក្រីក្រ

បំផុត និងប្រទេសតូចៗនៅក្នុងពិភពលោក ។ វានឹងក្លាយជាការចំអកពិតៗចំពោះធនាគារពិភពលោក ក្នុងការដក់ខ្លួនចេញពីប្រទេសដែលមានចំណូលមធ្យមនៅពេលដែលរដ្ឋាភិបាលទាំងនោះកំពុងតែទទួលស្គាល់តំរូវការសមាហរណកម្មប្រទេសទាំងនោះ ប្រកបដោយប្រសិទ្ធិភាពជាងមុនចំពោះការងារការទូត និងស្ថាប័នសន្តិសុខនយោបាយ : ហេតុអ្វីបានជាមិនបញ្ចូលពួកគេជាដៃគូនៅក្នុងស្ថាប័ននៃសេដ្ឋកិច្ចពហុភាគីផងទៅ?

កាលពី ២ ឆ្នាំ មុន ខ្ញុំបានស្នើរឡើងថា ប្រទេសចិន កសាងភាពជោគជ័យរបស់ខ្លួនដោយក្លាយទៅជា "អ្នកពាក់ព័ន្ធទទួលខុសត្រូវ" នៅក្នុងប្រព័ន្ធអន្តរជាតិ ។ ពិតណាស់មានការប្រឈមសំរាប់ប្រទេសដ៏ទៃទៀត ប្រសិនបើយើងចង់ទទួលឱ្យបានសកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថានមួយ ។ ក្នុងការងារទទួលខុសត្រូវនេះ ពួកគេគួរមានសំលេង និងតំណាង នៅក្នុងនោះ ។ យើងត្រូវការរបៀបវារៈឈានមុខមួយ ដើម្បីពង្រឹងការចូលរួមពីប្រទេសកំពុងអភិវឌ្ឍតាមរយៈការងារ និងពលកម្មរបស់ធនាគារពិភពលោក ។

ប្រទេសអភិវឌ្ឍន៍ ក៏ប្រឈមនឹងឱកាស និង ការប៉ះពាល់នៃសកលភាវូបនីយកម្មនេះដែរ ។ ប្រជាជនមានការព្រួយបារម្ភចំពោះក៏រិតនៃការផ្លាស់ប្តូរ ជាពិសេសបានកើតឡើងចំពោះក្រុមយុវជនជាច្រើន សម្របខ្លួននៅតាមភាពបទបែនដ៏អស្ចារ្យនេះ ។

គំនិតរួមនៃសាធារណៈជននៅប្រទេសអភិវឌ្ឍ នាំគេទៅរកការទទួលស្គាល់ថា ពុំមានជោគជ័យណាដោយសារការផ្តាច់ខ្លួនពួកគេឱ្យនៅឯកោនោះទេ ។ សុភាវធម៌រួម ក៏ដូចជាការគិតតែពីប្រយោជន៏ផ្ទាល់ខ្លួន នាំពួកគេឱ្យទទួលស្គាល់អន្តរអំពើពឹងអាស្រ័យគ្នាទៅវិញទៅមក ហើយឈានទៅរកការពិភាក្សាគ្នា ថាតើធ្វើយ៉ាងណាដើម្បីអនុលោមតាមវា ។

ក្នុងការប្រៀបធៀបទៅនឹងទំហំនៃការប្រឈមជាសកលទាំងនេះ ធនាគារពិភពលោក គឺជាស្ថាប័នសមហេតុផលមួយដើម្បីដោះស្រាយវា ។ ប៉ុន្តែការធ្វើការជាមួយដៃគូពហុភាគីរបស់ខ្លួន មាន អង្គការសហប្រជាជាតិ និងភ្នាក់ងារឯកទេសរបស់គេ មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងធនាគារអភិវឌ្ឍន៏តាមតំបន់ ធនាគារពិភពលោកត្រូវដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការឈានមុខក្នុងសកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និង មាននិរន្តរភាពបរិស្ថាន ។ ស្ថាប័នពហុភាគី ត្រូវតែចូលរួមគាំទ្រ ។ ពួកគេត្រូវការការរួបរួម ការផ្គត់ផ្គង់ជាមួយនឹងលទ្ធផលពោពេញទៅដោយប្រសិទ្ធិភាព ។ ពួកគេត្រូវជំនះនូវភាពទន់ខ្សោយផ្ទៃក្នុង និង កសាងភាពរឹងមាំរបស់គេ ។ ការចូលរួមធ្វើការទាំងអស់គ្នានេះ យើងត្រូវតែបង្ហាញឱ្យឃើញថា

ភាពជាពហុភាគីអាចធ្វើឱ្យការងារទាំងនោះមានប្រសិទ្ធិភាពកាន់តែប្រសើរ មិនមែនត្រឹមតែបង្ហាញនៅក្នុងបន្ទាប់សន្និសីទ និងសេចក្តីថ្លែងការនោះទេ ប៉ុន្តែស្តែងចេញនូវលទ្ធផលនៅតាមភូមិ និងទីក្រុងដែលមានប្រជាជនច្រើន ដែលពួកគេត្រូវការចាំបាច់ ។

សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និង មាននិរន្តរភាពបរិស្ថាន ត្រូវពន្លឿនឱ្យបានលឿនដោយស្ថាប័នពិភពលោក ។ ធនាគារពិភពលោក មានធនធានហិរញ្ញវត្ថុ មានបទពិសោធន៍ ចំណេះដឹង និងបុគ្គលិកដែលមានការលះបង់ខ្ពស់ ការបញ្ចុះបញ្ចូលអំណាច ប្រជាជនច្រើនជាង ១០០ ប្រទេស ហើយមានរដ្ឋជាសមាជិកចំនួន ១៨៥ ។ នៅពេលដ៏ប្រសើរមួយ ធនាគារពិភពលោកអាចកៀងគរធនធានផ្សេងៗទៀត ដូចជា ធនធានសាធារណៈ និងឯកជន ហិរញ្ញវត្ថុ និង ធនធានមនុស្ស ដើម្បីបង្កើតការបង្ហាញឱ្យឃើញនូវឥទ្ធិពល និង ឥទ្ធិពលដែលកើតមានឥតឈប់ឈរ ។ នៅពេលជោគជ័យ ធនាគារពិភពលោក ជាកាតាលីករមួយ សំរាប់ទីផ្សារថាវន្ត ដែលច្បាមយកឱកាសនៃសកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន ។

## ប្រធានបទជាយុទ្ធសាស្ត្រចំនួន ៦

តើអ្វី ហើយនៅពេលណា ការតំរង់ទិសជាយុទ្ធសាស្ត្ររបស់ធនាគារពិភពលោកគួត្រូវអនុលោមតាម?

ថ្ងៃនេះ ខ្ញុំនឹងលើកឡើងត្រួសៗចំពោះប្រធានបទជាយុទ្ធសាស្ត្រទាំង ៦ ការគាំទ្រគោលដៅសកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន ។ នៅសប្តាហ៍ខាងមុខ យើងនឹងប្រារព្ធកិច្ចប្រជុំបូកសរុបរវាងធនាគារពិភពលោក និង មូលនិធិហិរញ្ញវត្ថុអន្តរជាតិ ។ នៅក្នុងឱកាសនោះ ខ្ញុំសង្ឃឹមថា នឹងមានការពិភាក្សាលើប្រធានបទទាំង ៦ នេះ ឱ្យបានស៊ីជំរៅ ជាមួយនឹងទេសាភិបាលរបស់ធនាគារពិភពលោក ក៏ដូចជា ជាមួយនឹងសហគមន៍ដែលជាភាគីមានចំណាប់អារម្មណ៍លើប្រធានបទនេះ ដោយរួមទាំងសង្គមស៊ីវិល អ្នកជំនួញ និង មូលនិធិនានា ។

ទី ១ ធនាគារពិភពលោក ប្រយុទ្ធប្រឆាំងនឹងការប្រឈមនៃការជួយដោះស្រាយភាពក្រីក្រ និងជំរុញឱ្យមានកំណើនប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសក្រីក្រជាងគេ ជាពិសេសនៅក្នុងទ្វីបអាហ្វ្រិក ។ IDA ជាមធ្យោបាយហិរញ្ញវត្ថុស្នូលរបស់យើងសំរាប់ប្រទេសក្រីក្រជាងគេទាំង ៨១ ប្រទេស ។

នៅក្នុងប្រទេសទាំងនោះ យើងត្រូវការផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ ជាមួយនឹងដៃគូរបស់យើងស្តីអំពីការទទួលបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។ តំរូវការមូលដ្ឋានទាំងនេះ នឹងរៀបចំជាមូលដ្ឋានគ្រឹះសំរាប់អនាគត ។

ប៉ុន្តែ សារដែលខ្ញុំទទួលបាននៅពេលដែលខ្ញុំធ្វើដំណើរទៅទ្វីបអាហ្វ្រិកកាលពីខែមិថុនា និងទៅអាស៊ីកាលពីខែ សីហា គឺថា គោលដៅអភិវឌ្ឍន៍សង្គម គឺត្រូវការជាចាំបាច់ ប៉ុន្តែមិនគ្រាប់គ្រាន់ ។ ព័ត៌មានល្អ គឺថាប្រទេសនៅទ្វីបអាហ្វ្រិក ចំនួន ១៧ ដែលមានប្រជាជន ៣៦ ភាគរយ នៃតំបន់នេះ បានទទួលកំណើនប្រចាំឆ្នាំជាមធ្យម ៥.៥ ភាគរយ ពីឆ្នាំ ១៩៩៥ ដល់ ឆ្នាំ ២០០៥ ។ ប្រទេសទាំងនេះត្រូវការជំនួយដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំរាប់កំណើនខ្ពស់ជាងមុន ជាពិសេសក្នុងវិស័យថាមពល និង សំណង់រូបវន្ត ដែលអាចជួយគាំទ្រសមាហរណកម្មតំបន់ ។ ពួកគេត្រូវការយើងជួយអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមូលដ្ឋាន ដោយរួមទាំង មីក្រូហិរញ្ញវត្ថុ ដែលអាចជួយកៀងគរការសន្សំរបស់ប្រជាជនអាហ្វ្រិក សំរាប់កំណើននៅអាហ្វ្រិក ។

មេដឹកនាំនានានៅទ្វីបអាហ្វ្រិកសំលឹងឃើញសក្តានុពលនៃការពង្រីកកសិកម្ម ដោយបង្កើតតាមរយៈកំណើនផលិតកម្ម ។ របាយការណ៍អភិវឌ្ឍន៍ពិភពលោករបស់ធនាគារពិភពលោកដែលនឹងចេញផ្សព្វផ្សាយឆាប់ៗនេះ និងលើកឡើងថាកំណើនផលិតផលក្នុងស្រុកដែលបានមកពីវិស័យកសិកម្ម ផ្តល់អត្ថប្រយោជន៍ដល់អ្នកក្រីក្របំផុត ៤ ដង ច្រើនជាងវិស័យឯទៀតៗ ។ យើងត្រូវការការរៀបចំបដិវត្តបៃតងសតវត្សរ៍ទី ២១ សំរាប់ជាលក្ខណៈពិសេស និងតំរូវការផ្សេងៗគ្នានៃទ្វីបអាហ្វ្រិក ដោយការវិនិយោគនៅក្នុងស្រាវជ្រាវ និងការផ្សព្វផ្សាយបែបបច្ចេកវិទ្យា ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាព ចង្វាក់ផ្គត់ផ្គង់កសិកម្ម ប្រព័ន្ធធារាសាស្ត្រ ឥណទានមីក្រូជនបទ និង គោលនយោបាយដែលពង្រឹងឱកាសទីផ្សារ ដែលអាចជួយប្រជាជននៅជនបទដែលងាយរងគ្រោះ និងអសន្តិសុខ ។ ប្រទេសជាច្រើនទៀតត្រូវតែបើកចំហរទីផ្សាររបស់គេ សំរាប់ការនាំចេញផលិតផលកសិកម្ម ផងដែរ ។

ប្រទេស ៨ ផ្សេងទៀតនៅទ្វីបអាហ្វ្រិក ដែលមានប្រជាជន ប្រមាណ ២៩ ភាគរយ មានកំណើនមធ្យម ៧.៤ ភាគរយ ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៥ ដល់ ២០០៥ ដោយសារធនធានប្រេងរបស់គេ ។ សំរាប់ប្រទេសនេះ និង ប្រទេសខ្លះដែលទទួលបានការគាំទ្រដោយ IDA នៅតំបន់ឯទៀតៗ ភាពប្រឈមនៃការអភិវឌ្ឍជាអាទិភាព គឺការលើកទឹកចិត្តឱ្យមានអភិបាលកិច្ចល្អ និងគោលនយោបាយប្រឆាំងអំពើពុករលួយ

ជាមួយនឹងការពង្រឹកសមត្ថភាពវិស័យសាធារណៈនៅមូលដ្ឋាន ដើម្បីធានាថាចំណូលធនធាន ជួយកសាង ប្រទេសប្រកបដោយនិរន្តរភាពទៅអនាគត និងជាផលប្រយោជន៍ដល់ប្រជាជនទាំងអស់ ។

ទី២ យើងត្រូវដោះស្រាយបញ្ហាពិសេសចំពោះប្រទេសដែលទើបតែងើបពីជំលោះ ឬក៏ស្វែងរកជំនួយ ដើម្បីជៀសវាងការបែកបាក់នៅក្នុងប្រទេស ។

នៅពេលដែលទស្សនវិស័យនៅឯព្រិតុនវូត ដែលបង្កើតជា IBRD កាលពី ៦០ ឆ្នាំ មុន ពាក្យថា "R" មានន័យថាការស្តារឡើងវិញនៅអ៊ឺរ៉ុប និង ប្រទេសជប៉ុន ។ នៅពេលនេះ "R" បានចង្អុលបង្ហាញយើង ឱ្យជំនះនូវការប្រឈមនានាចំពោះការស្តារឡើងវិញនូវប្រទេសដែលទទួលរងគ្រោះដោយសង្គ្រាម ។

លោក Paul Collier បានសរសេរសៀវភៅរបស់គាត់មួយដែលមានចំណងជើងថា The Bottom Billion ដែលមានប្រជាជន ៧៣ ភាគរយ នៃប្រជាជនរាប់ពាន់លាននៅក៏រិតក្រោមបំផុត រស់នៅក្នុងប្រទេស ដែលមានសង្គ្រាមស៊ីវិល ។ ជាការសោកសៅបំផុត ជំលោះទាំងនេះ វាមិនត្រឹមតែនាំឱ្យប្រជាជនដែលចូលរួម ដោយផ្ទាល់រងទុកវេទនាប៉ុណ្ណោះទេ វាបានធ្វើឱ្យប៉ះពាល់ដល់អ្នកជិតខាង ឬប្រទេសជិតខាងផងដែរ ។

និយាយដោយត្រង់ ការយល់ដឹងរបស់យើងទាំងអស់គ្នា អំពីរបៀបដោះស្រាយករណីរមហន្តរាយ ទាំងនេះ គឺនៅមានកំរិត ។ ខ្ញុំរំពឹងថា យើងនឹងត្រូវការវិធីសាស្ត្រចំរុះបន្ថែមទៀត ក្នុងការចូលរួមនៅក្នុង រឿងរ៉ាវសន្តិសុខ ក្របខ័ណ្ឌគោលនយោបាយ ការកសាងឡើងវិញចំពោះសមត្ថភាពនៅជនបទឱ្យបានឆាប់ រហ័ស ការធ្វើសមាហរណកម្មជនភាសខ្លួនឡើងវិញ និង ជំនួយអភិវឌ្ឍន៍ប្រកបដោយភាពបទបែនបាន ។ ការ ងារកសាងរបស់ធនាគារពិភពលោកនៅប្រទេស បូសនី រ៉ូវ៉ាន់ដា និង មូស៊ាំប៊ិក បង្ហាញនូវអ្វីដែលអាចធ្វើទៅ បាន ។ ការទទួលយករបស់ IDA និងការបញ្ចេញហិរញ្ញវត្ថុបានលឿន បានផ្តល់សារៈសំខាន់យ៉ាងខ្លាំងសំរាប់ ប្រទេសដែលងើបពីជំលោះ ហើយយើងកំពុងតែធ្វើការជាមួយម្ចាស់ជំនួយ ដើម្បីបង្កើនប្រសិទ្ធិភាពការងារ របស់យើង ។

ពេលនេះ យើងធ្វើការនៅតំបន់ភាគខាងត្បូងប្រទេស សូដង់ លីបេរីយ៉ា លីបាណន់ សាធារណៈរដ្ឋកុង ហ្គោ បូរ៉ុនឌី អ៊ីរ៉ូវិកូស្ត អង់ហ្គោឡា ទិម័រលេស្តេ ប៉ាពួរញូគីណេ ប្រទេសក្នុងកោះប៉ាស៊ីហ្វិក អាបហ្គានីស្ថាន និង ហៃទី ហើយក្នុងចំណោមប្រទេសទាំងនោះ គឺជារឿយៗតាមរយៈមូលនិធិមរតកដែលបង្កើតឡើងដោយម្ចាស់ ជំនួយនានា ដោយមានការរួមកំលាំងពីអង្គការសហប្រជាជាតិ ។ ប្រសិនបើមានកិច្ចព្រមព្រៀងសន្តិភាពចូល

ជាធរមានមួយនៅដាហ្វួ ដែលគាំទ្រដោយកំលាំងសន្តិសុខដ៏រឹងមាំរបស់ UN-AU ធនាគារពិភពលោកនឹងចង់ជួយនៅទីនោះទៀត ។

ទី៣ ធនាគារពិភពលោកត្រូវការគំរូនៃការធ្វើជំនួញផ្សេងៗច្រើនថែមទៀតសំរាប់ប្រទេសដែលមានចំណូលមធ្យម ។ ប្រទេសទាំងនោះ បន្តជួបប្រទះនឹងការប្រឈមខ្លាំងសំរាប់ការអភិវឌ្ឍ ។ សេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ នៅតែពុំមានថវិកាគ្រប់គ្រាន់សំរាប់អភិវឌ្ឍន៍ ។ ក្នុងករណីជាច្រើន ការកើនឡើងកំណើនយ៉ាងឆាប់រហ័ស បានបរាជ័យក្នុងការផ្តល់ឱកាសដល់ប្រជាជនក្រីក្រ ។ បញ្ហាបរិស្ថាននៅតែមានទំហំធំធេង ។ ហើយនៅបន្តការលំបាកក្នុងលំហូរនៃទុនទៅដល់ប្រទេសទាំងនេះ ដូចជាប្រទេសដែលយើងបានឃើញចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨0 និង ១៩៩0 ។

ដោយការទទួលស្គាល់ករណីប្រឈមទាំងនេះ សមាជិកនៅក្នុងប្រទេសដែលមានចំណូលមធ្យមរបស់យើង ចង់ឱ្យធនាគារពិភពលោកបន្តចូលរួមជាមួយពួកគេតាមរយៈបង្កើតកម្មវិធី "ដំណោះស្រាយ ដើម្បីអភិវឌ្ឍន៍" ដោយមានការប្រកួតប្រជែង ។ ប៉ុន្តែការចូលរួមនេះត្រូវការឆ្លុះបញ្ចាំងទៅនឹងការកែលំអយ៉ាងប្រសើរនៅក្នុងជំហរហិរញ្ញវត្ថុរបស់គេ និង សមត្ថភាពស្ថាប័ននាទសវត្សរ៍កន្លងមក ។ ឧទាហរណ៍ថា ពួកគេចង់បាន IBRD ផ្តល់សេវាធនាគារដែលអាចមានលក្ខណៈបត់បែនជាងមុន និងមានតំលៃប្រសើរ (ថោក) ហើយបន្ថយការិយាធិបតេយ្យ និងឆ្លើយតបឱ្យបានយ៉ាងឆាប់រហ័ស ។ ពួកគេកំពុងសំលឹងមើល IFC ដើម្បីជួយអភិវឌ្ឍដំណោះស្រាយវិស័យឯកជន សំរាប់ទីផ្សារមិនមានការអភិវឌ្ឍ និង ជាតំរូវការឱ្យមានសេវាសង្គមប្រសើរ ។ ពួកគេ កំពុងតែជំរុញឱ្យយើងបង្កើនស្តង់ដារគុណភាពប្រសើរជាងមុន សមស្របនឹងកាលៈទេសៈ និងប្រសិទ្ធិភាពនៃតំលៃ ចំពោះសេវាប្រឹក្សារបស់យើង ។ សរុបមក ពួកគេចង់ឱ្យមានដំណើរការ ហើយចំណុចនេះហើយ គឺជាអ្វីដែលយើងមានបំណង ដើម្បីផ្តល់ឱ្យពួកគេ ។

សំរាប់ប្រទេសដែលមានចំណូលមធ្យមខ្លះ សេវាកម្មរបស់យើង និងកើនឡើងនៅក្នុងវិស័យគ្រប់គ្រងហានិភ័យ និងការប្រើប្រាស់ជំនាញជាសកលដើម្បីតំរូវការមូលដ្ឋាន ។ យើងអាចផ្តល់ការលើកកំពស់ឥណទាន  ការការពារ និង ជំនាញដែលមាន សំរាប់ជួយកសាងសមត្ថភាពគ្រប់គ្រងទ្រព្យសកម្ម ។ យើងអាចលើកទឹកចិត្តឱ្យមានទីផ្សារសន្តិសុខមូលដ្ឋាន ដោយជួយកសាងមូលនិធិមូលប័ត្ររូបិយវត្ថុ និងការណែនាំ ។ យើងអាចផ្តល់ហិរញ្ញវត្ថុដល់រូបិយវត្ថុមូលដ្ឋានដើម្បីជួយភ្ជាប់កម្មវិធីកម្ចីរបស់យើងជាមួយនឹងការគ្រប់គ្រងហានិភ័យខាងរូបិយវត្ថុ ។ ដើម្បីលើកទឹកចិត្តកំណើនដោយមានការចូលរួមនៅក្នុងប្រទេស យើងអាចធ្វើការ

ជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិ ។ យើងពេលនេះកំពុងតែបង្កើតមធ្យោបាយហិរញ្ញវត្ថុ អាស្រ័យគ្នាទៅវិញទៅមក ដើម្បីជួយគាំទ្រការជាបន្ទាន់នូវសន្ទនិយភាព ( ទ្រព្យសកម្មងាយស្រួលប្តូរយកសាច់ប្រាក់) ក្នុងពេលដែលពួកគេជួបបញ្ហា ហិរញ្ញវត្ថុ ក៏ដូចជាការធានារ៉ាប់រងទីផ្សារ ដើម្បីឱ្យមានភាពទូលំទូលាយ និងកាត់បន្ថយតំលៃចំពោះគ្រោះមហន្តរាយធម្មជាតិ ដូចជា ព្យុះហើរីខេន និងរំជួយដី ។ សកម្មភាពខ្លះ ប្រហែលជាអាចនាំឱ្យយើងបង្ហាញ នូវរបៀបរបបដ៏ប្រសើរសំរាប់ផ្តល់សេវា និងចំណេះដឹងសំរាប់កំរៃដើម្បីផ្តល់ឱ្យប្រទេសដែលជាអតិថិជន របស់យើងនូវជំរើសមួយនៃការផ្គង់ផ្គង់ដោយមាន ឬ ដោយមិនមានហិរញ្ញវត្ថុ ។

ទី ៤ ធនាគារពិភពលោក ត្រូវដើរតួយ៉ាងសកម្មថែមទៀតក្នុងការពន្លឿនទ្រព្យសម្បត្តិសាធារណៈ ទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក ដែលបើកព្រំដែននៃប្រទេសនីមួយៗ ហើយផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាច្រើន និង ប្រជាពលរដ្ឋរបស់គេ ។ វាគឺជាការអំពាវនាវរបស់យើង ដើម្បីធានាថា របៀបវារៈនេះ គឺមានទំនាក់ទំនងទៅនឹងគោលបំណងនៃការអភិវឌ្ឍ ។

ធនាគារពិភពលោក បានបង្ហាញឱ្យឃើញរួចរាល់ហើយនូវសក្តានុពល ដើម្បីជួយប្រឆាំងនឹងជំងឺឆ្លងតាមរយៈការងាររបស់យើងចំពោះជំងឺ HIV/AIDS គ្រុនចាញ់  គ្រុនផ្តាសាយបក្សី និងការអភិវឌ្ឍថ្នាំវ៉ាក់សាំងចាក់បង្ការោគ ។ យើងកំពុងតែស្ថិតនៅចំកណ្តាលវិធីនៃការពិនិត្យមើលឡើងវិញ ដើម្បីពង្រឹងទំនាក់ទំនងគ្នារវាងជំនួយ និង ពាណិជ្ជកម្ម ( ដោយរួមទាំងគំរោងហិរញ្ញវត្ថុពាណិជ្ជកម្មស្តីអំពីគំនិតថ្មីៗរបស់ IFC) ដោយផ្តោតទៅលើប្រទេសនៅអាហ្វ្រិក ដែលនៅក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះយើងបានគាំទ្រជាទឹកប្រាក់ប្រមាណជិត ២ ពាន់លាន ដុល្លារ ចំពោះពាណិជ្ជកម្ម ។

យើងកំពុងតែធ្វើការជាមួយក្រុមប្រឹក្សាភិបាលរបស់យើង ចំពោះជំហានដ៏សំរាប់ជំនួយរបស់យើងទៅដល់កិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាបំរែបំរួលអាកាសធាតុ ។ នៅក្នុងកិច្ចប្រជុំបូកសរុបរបស់យើងដែលនឹងធ្វើនៅពេលខាងមុខបន្តិចទៀតនេះ និងនៅឯសន្និបាតបំរែបំរួលអាកាសធាតុ របស់អង្គការសហប្រជាជាតិដែលនឹងប្រារព្ធធ្វើឡើងនៅកោះបាលីនាខែធ្នូនេះ ខ្ញុំសង្ឃឹមថា នឹងមានឱកាសលើកពីគោលបំណងចំពោះគំរោងដែលធនាគារពិភពលោកអាចជួយដាក់បញ្ចូលនូវគាំទ្រការនៃការអភិវឌ្ឍ និងធ្វើឱ្យមានកំរិតទាបនៃកំណើនបំភាយឧស្ម័នកាបូនិច ។ យើងត្រូវតែផ្តោតការយកចិត្តទុកដាក់របស់យើងជាពិសេស ចំពោះ ចំណាប់អារម្មណ៍របស់ប្រទេសកំពុងអភិវឌ្ឍ ដូចនេះយើងអាចដោះស្រាយបញ្ហាប្រឈមនៃបំរែបំរួលអាកាសធាតុ ដោយមិនធ្វើឱ្យអាក់ខានដល់កំណើនដែលវាអាចជួយដល់ការកាត់បន្ថយភាពក្រីក្រ ។

ការងាររបស់យើងស្តីអំពីទ្រព្យសម្បត្តិសាធារណៈនៅក្នុងតំបន់ និង នៅលើសកលលោក នឹងទាមទារឱ្យមានកិច្ចសហការដ៏ជិតស្និតជាមួយភ្នាក់ងារដែលមានជំនាញឯកទេស ដូចជា WHO, UNEP, UNODC និង WTO ។ យើងក៏ត្រូវតែកំណត់ឱកាសការងាររបស់យើង ដើម្បីផ្តោតសំខាន់ ជាពិសេស លើធនធានរបស់យើង តាមរយៈវិធីសាស្ត្រជ្រើសរើសឱ្យចំៗ និង អវិកលកម្ម (ភាពផ្សេងគ្នា) ។ ដោយសារឯកទេសរបស់យើងចំពោះការងារអភិវឌ្ឍន៍នៅកំរិតជាតិ បញ្ហាប្រឈមនៃប្រតិបត្តិការដ៏សំខាន់របស់យើង គឺការគាំទ្រប្រទេសនោះ ដែលពួកគេបានកំណត់ពីរបៀបរបបដ៏ប្រសើរដើម្បីបញ្ចូលគោលនយោបាយទ្រព្យសម្បត្តិសាធារណៈ ព្រមទាំងឱកាសតំបន់ និង ពិភពលោក ទៅក្នុងកម្មវិធីជាតិរបស់គេ ។ ឱកាសទាំងនេះ គួបញ្ចូលវិស័យឯកជនលើសហគ្រិន និង ថាមពល ផងដែរ ។

ទី ៥ ចំណុចមួយនៃការប្រឈមដ៏តានតឹងនានាដែលយើងអាចកត់សំគាល់បាននៃពេលវេលារបស់យើង គឺថាតើយើងគាំទ្រចំពោះប្រទេសនៅពិភពអារ៉ាប់យ៉ាងណាចំពោះការស្វែងរកភាពជឿនលឿននៃការអភិវឌ្ឍ និង ឱកាស ។ កាលពីអតីតកាល តំបន់ទាំងនោះ ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និង ការរៀនសូត្រ ហើយពេលនេះប្រទេសទាំងនោះមានសក្តានុពលច្រើន ប្រសិនបើគេអាចផ្លាស់ប្តូរឈានឱ្យចេញពីបញ្ហា និង ឧបសគ្គរារាំងនានា ដើម្បីកំណើន និង ការអភិវឌ្ឍសង្គម ។ ដោយគ្មានកំណើនដ៏ទូលំទូលាយ ប្រទេសទាំងនោះ នឹងប្រឈមនឹងភាពតានតឹងនៅក្នុងសង្គម ហើយចំនួនមនុស្សពេញវ័យដ៏ច្រើនលើសលុប គ្មានការងារ ។ របាយការណ៍អភិវឌ្ឍន៍មនុស្សនៅអារ៉ាប់ដែលធ្វើឡើងដោយអង្គការសហប្រជាជាតិ ផ្តល់សារៈសំខាន់សំរាប់ការធ្វើស្វ័យវាយតំលៃដោយខ្លួនឯង ។

កាលពីពេលដែលខ្ញុំបំរើការងារជាតំណាងផ្នែកពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ខ្ញុំបានធ្វើការយ៉ាងជិតស្និតជាមួយមេដឹកនាំជាច្រើន ពីភូមិភាគ Maghreb ទៅដល់ឈូងសមុទ្រ ដែលជាកន្លែងបើកចំហរសេដ្ឋកិច្ច និង សង្គម ។ ប្រទេសខ្លះមានធនធានថាមពល និង ទុនមហាសាល ប៉ុន្តែនានាភាពខាងសេដ្ឋកិច្ច និង លទ្ធភាពតិចតួចណាស់ដើម្បីបង្កើតការងារ ។ ប្រទេសខ្លះ ពេលនោះ ស្វែងរកការកែលំអសាលារៀន ពង្រឹងនៃការទទួលយកបច្ចេកវិទ្យា និង ពង្រីកការងារ តាមរយៈជំនួញមិនច្បាស់លាស់ និង តាមរយៈពាណិជ្ជកម្ម ។ នៅពេលនោះ ប្រទេសមួយចំនួន អាស្រ័យលើផលិតកម្មដែលភ្ជាប់ទៅនឹងប្រទេសនៅអាស៊ី តាមរយៈការវិនិយោគឆ្លងប្រទេស ពាណិជ្ជកម្ម និងកំណើនមជ្ឈមណ្ឌលសេវាកម្ម ។

របាយការណ៍ "ធ្វើអាជីវកម្មឆ្នាំ ២០០៨" របស់យើងនាពេលថ្មីៗនេះ បានបង្ហាញថា មានដំណើរការប្រសើរ ។ ប្រទេសអេស៊ីប ស្ថិតនៅកំពូលនៃតារាងនៃនិយតកម្មកំណែទំរង់សេដ្ឋកិច្ចដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងការងារអាជីវកម្ម ។ ប្រទេស អារ៉ាប៊ី សាវឌី បានបំបាត់ចោលនូវការិយាធិបតេយ្យដែលធ្លាប់ធ្វើឱ្យប្រទេសនេះ ជាប្រទេសលំបាកជាងគេបំផុតក្នុងការធ្វើអាជីវកម្ម ហើយក៏បានបន្ថយតំរូវការដើមទុនឱ្យនៅកំរិតអប្បរមា ។

មានការលើកទឹកចិត្តចំពោះការអភិវឌ្ឍ ប៉ុន្តែក៏នៅមានការងារជាច្រើនទៀតដែរដែលត្រូវធ្វើ ។ សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ ត្រូវតែផ្តល់អត្ថប្រយោជន៍សំរាប់ប្រជាជនទាំងអស់នៅក្នុងតំបន់នេះ ។ ដូចដែលរដ្ឋាភិបាលនានានៃពិភពអារ៉ាប ស្វែងរកការផ្តល់សេវាសង្គមប្រកបដោយប្រសិទ្ធិភាពដល់ប្រជាជនរបស់គេទាំងអស់គ្នា យើងអាចផ្តល់បទពិសោធន៍ដែលអាចប្រៀបធៀបបាន ។ យើងអាចជួយក្នុងការបង្កើតបរិយាកាសស្វាគមន៍សំរាប់ការធ្វើអាជីវកម្ម ទាំងអ្នកនៅក្នុងប្រទេស និង ពីបរទេស ។ ក្នុងករណី ខ្លះយើងប្រហែលជាអាចផ្តល់ហិរញ្ញវត្ថុសំរាប់គំរោងអភិវឌ្ឍន៍ ប្រតិបត្តិមូលនិធិមរតករបស់ម្ចាស់ជំនួយ ឬ ជួយពង្រីកសេវាកម្មវិស័យឯកជនតាមរយៈកម្មវិធីរបស់ IFC ។ នាពេលនេះ យើងកំពុងតែជួយផ្តល់សេវាសង្គមមូលដ្ឋាន និង គាំទ្រអភិបាលកិច្ចល្អ និងកំណើនវិស័យឯកជន នៅប៉ាលេស្ទីន ដែលអាចផ្តល់មូលដ្ឋានគ្រឹះសេដ្ឋកិច្ចសំរាប់ជាក្តីសង្ឃឹម ប្រសិនបើភាគីទាំងអស់ជ្រើសរើសយកមាគ៌ាសំរាប់សន្តិភាព ។

ចុងក្រោយ ខណៈដែលធនាគារពិភពលោកមានកំរិតខាងហិរញ្ញវត្ថុ និងអាជីវកម្មសំរាប់ការអភិវឌ្ឍ យើងសូមឱ្យមានការចូលរួមច្រើនពីអ្នកឯទៀត ។ ធនាគារពិភពលោក គឺជាស្ថាប័នតែមួយ និង ពិសេសសំរាប់ចំណេះដឹង និង មេរៀន/បទពិសោធន៍ ។ ធនាគារពិភពលោក ប្រមូល និង ចែកចាយទិន្នន័យ ដ៏មានតំលៃ ។ ប៉ុន្តែវាមិនមែនជាសាកលវិទ្យាល័យទេ វាជា "ទីបណ្តុំខួក្បាល brain trust ( ក្រុមជំនាញផ្តល់មតិយោបល់សំរាប់គោលនយោបាយ និង យុទ្ធសាស្ត្រ" នៃបទពិសោធន៍ដែលអាចយកទៅអនុវត្តបាន ដែលនឹងជួយយើងដោះស្រាយប្រធានបទជាយុទ្ធសាស្ត្រទាំង ៥ ខាងលើ ។

សមត្ថភាពនេះ ទាមទារឱ្យមានការទទួលស្គាល់ និង ការគាំទ្រជាពិសេស ។ ប៉ុន្តែយើងក៏ត្រូវតែបន្តចោទសួរខ្លួនយើងថា : តើអ្វីដែលនាំឱ្យយើងទទួលបានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ និង មាននិរន្តរភាពបរិស្ថាន និងមានកំណើន?

ការប្រឈមនេះ ទាមទារឱ្យមានសេចក្តីគោរព និងភាពស្មោះត្រង់នៃបញ្ហា ។ គំរោង និង សុបិន នៃការអភិវឌ្ឍជាច្រើន បានទទួលបរាជ័យ ។ នេះមិនមែនជាហេតុផលនៃការបញ្ឈប់ការព្យាយាមនោះទេ ។ វាគឺបង្កឱ្យយើងបន្ត និងម៉ឺងម៉ាត់នៃការផ្តោតការយកចិត្តទុកដាក់លើលទ្ធផល និង ការវាយតំលៃលើប្រសិទ្ធិភាពការងារ ។ នេះជាមធ្យោបាយដ៏ប្រសើរសំរាប់ជាការទុកចិត្ត និង គាំទ្រ ពីម្ចាស់ភាគហ៊ុន និងអ្នកពាក់ព័ន្ធរបស់យើង ក៏ដូចជាអចិតិជន និងដៃគូអភិវឌ្ឍន៏ដែរ ។

ប្រធានបទជាយុទ្ធសាស្រ្តទាំង ៦ នេះ ផ្តល់ជាទិសដៅមួយ ហើយយើងត្រូវពិភាក្សា ការពិនិត្យឱ្យបានល្អិតល្អន់ឡើងវិញ និងការកែលំអវា ។ ដើម្បីពាំនាំគំនិតទាំងនេះ ឱ្យក្លាយទៅជាផ្លែផ្កា យើងត្រូវតែយល់ដឹងអំពីតំរូវការពិស្តារពីអចិតិជនរបស់យើង ។ យើងសូមស្វាគមន៏ចំពោះមតិយោបល់ និង ការណែនាំពីម្ចាស់ភាគហ៊ុនរបស់យើង ។ មានតំរូវការដ៏ប្រសើរមួយ និងឱកាស សំរាប់ធនាគារពិភពលោកនៅចំណុចនេះ ហើយនេះជាប្រវត្តិសាស្រ្ត ។

## ការប្រឈមផ្ទៃក្នុងៈ អភិបាលកិច្ចល្អ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

ដើម្បីទទួលបានជោគជ័យ ធនាគារពិភពលោកត្រូវតែជំនះឱ្យបាននូវបញ្ហាប្រឈមផ្ទៃក្នុងរបស់ខ្លួន ។ យើងត្រូវតែប្រើប្រាស់ទុនរបស់យើងឱ្យមានប្រសិទ្ធិភាពថែមទៀត និង ផ្តោតបន្ថែមលើសេវាអតិថិជន ។ យើងគួតែពង្រឹងទំនាក់ទំនងរបស់យើងជាមួយអង្គការសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាល ដូចនេះយើងអាចរៀនសូត្របានពីពួកគាត់ ។ ឆ្លុះបញ្ចាំងទៅនឹង "ស្ថាបត្យកម្មនៃជំនួយ" ថ្មី យើងត្រូវតែធ្វើការឱ្យមានប្រសិទ្ធិភាពថែមទៀតជាមួយកម្មវិធីជំនួយជាតិ មូលនិធិទាំងនោះផ្តោតលើគំរោងពិស្តារ ដូចជា ជំងឺ មូលដ្ឋានគ្រឹះនានា អង្គការមិនមែនរដ្ឋាភិបាលនៅតាមប្រទេស និង អាជីវកម្មវិស័យឯកជនដែលមានចំណាប់អារម្មណ៏នៅក្នុងការអភិវឌ្ឍប្រកបដោយការប្រឈមទាំងនេះ ។

យើងត្រូវតែជួយបុគ្គលិកឱ្យមានការអភិវឌ្ឍវិជ្ជាជីវៈប្រសើរ និងការកែលំអការចល័តនៅក្នុងអង្គការរបស់យើង ។ យើងត្រូវការគោលនយោបាយធនធានមនុស្សដ៏រឹងមាំ ដើម្បីគាំទ្របុគ្គលិករបស់យើងនៅតាមប្រទេស ដោយយើងលើកទឹកចិត្តចំពោះការធ្វើវិមជ្ឈការឱ្យបានប្រសើរ ។ យើងត្រូវការសំលេង និងតំណាងច្រើនថែមទៀតពីក្រុមប្រឹក្សារបស់យើង និង នានាភាពនៅក្នុងកំលាំងការងាររបស់យើង ។

ដូចដែលរបាយការណ៍ថ្មីៗមួយនៃបទពិសោធន៍គណៈវិនិច្ឆ័យមួយ ដែលដឹកនាំដោយអតីតប្រធានក្រុមប្រឹក្សា Federal Reserve លោក Paul Volcker គូសបញ្ជាក់ យើងក៏ត្រូវតែពង្រឹងវិធីសាស្ត្ររបស់យើង ដើម្បីដោះស្រាយបញ្ហាអភិបាលកិច្ច និង អំពើពុករលួយ ។ គណៈវិនិច្ឆ័យបានផ្តល់ឱ្យយើងនូវអនុសាសន៍ដ៏មានតំលៃ ដើម្បីពិចារណាគាំទ្រការងារអ្នកស៊ើបអង្កេតផ្ទៃក្នុងរបស់យើង និង ធានាថា សមិទ្ធផលរបស់គេត្រូវបានប្រើប្រាស់ជាពិសេស ។ យើងប្រតិបត្តិតាមជាបន្ទាន់ និងការស្វាគមន៍ទស្សនៈផ្សេងៗ និងការពិភាក្សាគំនិតទាំងនេះជាមួយក្រុមប្រឹក្សារបស់យើង នឹងឈានឆ្ពោះទៅរកការកែលំអប្រតិបត្តិការរបស់យើង ។

តាមបទពិសោធន៍របស់ខ្ញុំ ខ្ញុំឃើញថា បុគ្គលិករបស់ធនាគារពិភពលោកទទួលស្គាល់អំពីសារៈសំខាន់នៃរបៀបវារៈអភិបាលកិច្ច និង ការប្រឆាំងនឹងអំពើពុកលួយ ។ ពួកគេមានមោទនភាពចំពោះបេសកកម្មអភិវឌ្ឍន៍ដែលគេកំពុងបំរើ និងចង់លើកកំពស់សុចរិតភាពនៃស្ថាប័នរបស់គេ ហើយបានដឹងថា អំពើពុករលួយបានលួយផលប្រយោជន៍ដ៏ច្រើនបំផុតពីអ្នកក្រ និង អ្នកដែលគ្មានអំណាច ។ យើងនឹងធ្វើឱ្យមានលក្ខណៈប្រសើរជាមួយគ្នា។

ធនាគារពិភពលោក អាចផ្តល់ភាពជាអ្នកដឹកនាំ ដោយដាក់បញ្ចូលគោលនយោបាយអភិបាលកិច្ចល្អ និង នីតិរដ្ឋ ទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ ។ គ្រាន់តែខែមុននេះ យើងបានចូលរួមជាមួយ អង្គការសហប្រជាជាតិ ផ្សព្វផ្សាយ គំនិតផ្តួចផ្តើម ការស្រោចស្រង់ឡើងវិញចំពោះទ្រព្យសម្បត្តិដែលគេបានលួច (StAR) ដើម្បីឱ្យប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ ធ្វើការជាមួយគ្នា ដើម្បីសង្គ្រោះឡើងវិញនូវ ការលួចប្លន់ហិរញ្ញវត្ថុដោយអំពើពុករលួយ ។ របាយការណ៍ ***ការធ្វើអាជីវកម្ម*** របស់យើង បានបង្ហាញយ៉ាង ច្បាស់ថា គោលនយោបាយនិយតកម្ម និង ការផ្តល់អាជ្ញាប័ននៅខ្សោយ មិនត្រឹមតែបង្អាក់សហគ្រិននោះទេ វាថែមទាំងបង្កើតឱកាសឱ្យមានការលួចយកធនធាននានា ។

## <u>សេចក្តីសន្និដ្ឋានៈ សំលេងពីរ</u>

នៅថ្ងៃនេះ ខ្ញុំបានផ្តល់នូវទស្សនៈជាទិសដៅសំរាប់ធនាគារពិភពលោក ។ ដើម្បីស្វែងយល់អំពីអ្វីដែលយើងធ្វើ សូមមេត្តាអនុញ្ញាតឱ្យខ្ញុំបញ្ចប់សន្ទរកថារបស់ខ្ញុំដោយលើកយកសំលេងពីរ ពីអ្នកភូមិពីររូប ។

ឌីរាមម៉ា គឺជាស្ត្រីម្នាក់ជាសមាជិកក្នុងក្រុមជួយខ្លួនឯងក្នុងភូមិមួយនៅរដ្ឋ អាន់ឌ្រា ប្រាដេស របស់ប្រទេសឥណ្ឌា ។ នាង គឺអាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីច្រើនជាង ៨ លាននាក់ ដែលទទួលបានការគាំទ្រដោយ

ធនាគារពិភពលោក បង្កើតជាក្រុមជួយខ្លួនឯង ដើម្បីសន្សំធនធានរួមគ្នា ។ ការជួយអន្តរាគមន៍ជាមូលដ្ឋាន និង សេវាគាំទ្រដ៏មានសារៈសំខាន់នេះ បានបង្កើនចំណូលជិត ៩០ ភាគរយ ចំពោះប្រជាជននៅជនបទ ដែលមានប្រមាណជិត ៤០ លាននាក់ ។ អ្នកស្រីជីវាមម៉ា ប្រាប់យើងថា "យើងធ្លាប់តែរកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក ។ ប៉ុន្តែពេលនេះ យើងអាចពឹងពាក់លើខ្លួនយើងបាន និងអាចឱ្យកូនៗទៅរៀនបានទៀតផង ។ ពេលនេះ យើងមានទំនុកចិត្តថា យើងអាចឈានជើងចេញពីភាពក្រីក្រ" ។

អ្នកស្រី ឪណាល្វា មួរ៉ា ម្តាយដែលមានកូនបីនាក់ ហើយជាសមាជិកកម្មវិធី Bolsa Familia របស់ប្រទេសប្រេស៊ីល ដែលផ្តល់ថវិកាខ្នាតតូចដល់ឪពុកម្តាយ ប្រមាណ ១១ លាន គ្រួសារ ដើម្បី ឱ្យកូនៗរបស់គេទៅរៀន និង ទៅពិនិត្យសុខភាពជាទៀងទាត់ ។ ធនាគារពិភពលោក ផ្តល់ហិរញ្ញវត្ថុ និង ជំនួយបច្ចេកទេសគាំទ្រគំនិតផ្តួចផ្តើមដ៏មានសារៈសំខាន់របស់រដ្ឋាភិបាលប្រទេសប្រេស៊ីល ។ អ្នកស្រី ឪណាល្វា បានជំរាបប្រាប់យើងថា "កម្មវិធី Bolsa Familia ជួយខ្ញុំទិញស្បៀងអាហារ ពេលខ្លះខ្ញុំអាចទិញផ្លែឈើឱ្យកូនៗហូប ។ ពួកគេមិនគេចសាលាទេ ដោយសារពួកគេដឹងថា លុយនេះគឺបានមកអាស្រ័យទៅនឹងការទៅរៀនរបស់ពួកគេ" ។

ទាំងនេះ គឺជាសំលេងដែលប្រាប់អ្នកអំពីរឿងរ៉ាវនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីបង្កើតភាពដែលអាចធ្វើបានថ្មីសំរាប់អ្នកក្រ ។ ទាំងនេះ គឺជាសំលេងដែលបន្ទរអំពីតំរូវការសំរាប់ជាកំលាំងមួយដែលធនាគារពិភពលោក នឹងភ្ជាប់សំលេងទាំងនេះទៅប្រជាជនផ្សេងៗទៀត ទៅនឹងគំនិតនានា និង ទៅឱកាសផ្សេងទៀត ។ នេះហើយគឺជាអ្វីដែលយើងចង់មានន័យថា សកលភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាពបរិស្ថាន ។